ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ១៣ / ៩៩

ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៩

**សេចក្តីសំរេច**

លេខ : ១៣ ករធ.សសរ.ច

ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៩

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសំណើសុំអោយពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ស្តីពីរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៩ របស់ក្រុមអ្នកតំណាងរាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបាននៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ១៩ សីហា ឆ្នាំ ១៩៩៩

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាគ្រប់ជ្រុងជ្រោយហើយ**

- យល់ឃើញថា ពាក្យបណ្តឹងរបស់អ្នកតំណាងរាស្ត្រចំនួន ១៣ រូប ធ្វើបានត្រឹមត្រូវតាមទំរង់ច្បាប់ ព្រមទាំង ត្រូវនឹងគតិច្បាប់ ។
- យល់ឃើញថា ព្រះរាជាណាចក្រកម្ពុជា បានប្រកាសសច្ចាប័នលើអនុសញ្ញាស្តីពីការបង្ក្រាប និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៥០ ដោយ សម្តេច **ស៊ឹម វ៉ារ** រដ្ឋមន្ត្រីក្រសួងការបរទេស ហើយចូលជាធរមានថ្ងៃទី ១៤ ខែមករា ឆ្នាំ ១៩៥១ ។
- យល់ឃើញថា ក្រឹត្យច្បាប់លេខ ០១ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៩ ស្តីពីការបង្កើតតុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញ ដើម្បីជំនុំជំរះអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ពួក ប៉ុលពត-អៀងសារី ក៏បានកំណត់អំពីទោសនៃបទប្រល័យពូជសាសន៍នេះដែរ ត្រង់ចំណុច ១ មាត្រា ២ ។
- យល់ឃើញថា ការឃុំខ្លួនជាបណ្តោះអាសន្ន ទោះជារយៈពេលប៉ុន្មានក៏ដោយ អោយតែមានកំណត់

ក្នុងច្បាប់ ហើយអនុវត្តត្រឹមត្រូវតាមនីតិវិធីនៃការឃុំខ្លួនជាបណ្តោះអាសន្ននោះ មិនត្រូវចាត់ទុកថាជាមនុស្សមានទោសទេ ព្រោះក្នុងរយៈពេលនេះ តុលាការគ្រាន់តែធ្វើការស៊ើបអង្កេតរកឱ្យបានគ្រប់ជ្រុងជ្រោយមុននឹងឈានដល់ការជំនុំជម្រះ ថាតើសាមីខ្លួនមានទោស ឬ គ្មានទោសប៉ុណ្ណោះ ។ ដូច្នេះមិនមានអ្វីប្រឆាំងនឹងវាក្យខណ្ឌទី ៧ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១-** ច្បាប់ស្តីពីរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ២ និងព្រឹទ្ធសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំពេញអង្គវិសាមញ្ញ នីតិកាលទី ១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ចាន់ សុខ